គណៈកម្មាធិការដើម្បីការបោះឆ្នោតដោយសេរី និងយុត្តិធម៌ នៅកម្ពុជា

Committee for Free and Fair Elections in Cambodia

ខុមហ្វ្រែល COMFREL

ថ្ងៃទី១៨ ខែកក្កដា ឆ្នាំ២០១៣

# កម្មវិធីព័ត៌មានសម្លេងម្ចាស់ឆ្នោតសម្រាប់ប្រើប្រាស់លើទូរស័ព្ទដៃ

ដើម្បីចូលរួមលើកកម្ពស់ការផ្សព្វផ្សាយព័ត៌មានបោះឆ្នោត និងអប់រំអ្នកបោះឆ្នោតតាមរយៈបច្ចេកវិទ្យាពិសេស ឆ្លើយតបនឹងកំណើនទូរស័ព្ទដៃក្នុងប្រទេសកម្ពុជា គណៈកម្មាធិការខុមហ្វ្រែល បានផលិត **កម្មវិធីព័ត៌មានបោះឆ្នោត ឬសម្លេងម្ចាស់ឆ្នោតកម្ពុជាមួយ សម្រាប់ប្រើប្រាស់លើទូរស័ព្ទ** ( Android-អេនដ្រយដ៍ and IOS- អាយហ្វូន) ដោយចែកផ្សាយជូនជា សាធារណៈចាប់ពីដើមខែកក្កដា ឆ្នាំ២០១៣នេះហើយ។

លក្ខណៈពិសេសរបស់ កម្មវិធីព័ត៌មានសម្លេងម្ចាស់ឆ្នោត សម្រាប់ប្រើលើទូរស័ព្ទដៃនេះ គឺ ជំនួយអោយអ្នកប្រើប្រាស់ទូរស័ព្ទដៃ អាចអានព័ត៌មាន និងវិដេអូបោះឆ្នោតថ្មីៗ ជាភាសាខ្មែរបាន ទោះបីជា ទូរស័ព្ទលោកអ្នកគ្មានអក្សរខ្មែរក៏ដោយ។ កម្មវិធីព័ត៌មានសម្លេងម្ចាស់ឆ្នោតកម្ពុជា សម្រាប់ប្រើប្រាស់លើទូរស័ព្ទ អាចរកបាននៅលើ Google Play/Android Market (ទូរស័ព្ទដៃអេនដ្រយដ៍) និងApp Store/iTunes Store (ទូរស័ព្ទដៃអាយហ្វូន) ដោយគ្រាន់តែលោកអ្នកស្រាវជ្រាវរកពាក្យ comfrel ហើយធ្វើការដោនឡូត ដោយមិនគិតថ្លៃ មកតម្លើងក្នុងទូរស័ព្ទដៃរបស់លោកអ្នកជាការស្រេច។

ចំពោះ **កម្មវិធីព័ត៌មានសម្លេងម្ចាស់ឆ្នោតកម្ពុជា សម្រាប់ទូរស័ព្ទដៃអេនដ្រយដ៍** នឹងជំនួយដល់ ម្ចាស់ឆ្នោតក្នុងការអានព័ត៌មានបោះឆ្នោតថ្មីបំផុតជាភាសាខ្មែរ ទស្សនាវិដេអូអប់រំបោះឆ្នោតចុងក្រោយបំផុតជាភាសាខ្មែរ តាមដានលទ្ធផលបោះឆ្នោតរហ័សបំផុតជាភាសាខ្មែរ ផ្ញើសារ SMS និងអ៊ីម៉ែល មកកាន់ក្រុមការងារសម្លេងម្ចាស់ឆ្នោតកម្ពុជា ដើម្បីស្នើសុំជំនួយបច្ចេកទេសបោះឆ្នោត។ កម្មវិធីនេះ មានដាក់អោយ ម្ចាស់ឆ្នោត ដោនឡូត នៅលើទីផ្សារ ហ្គូហ្គល ឬ គេហទំព័រ សម្លេងម្ចាស់ឆ្នោតកម្ពុជា www.cambodianvotervoice.org ដោយមិនគិតប្រាក់ ហើយអាចតម្លើងប្រតិបត្តិការណ៍ នេះបាននៅលើ ទូរស័ព្ទដៃ ប្រភេទ អេនដ្រយដ៍ ចាប់ពី version ២.២ ឡើងទៅ។ ដើម្បីស្វែងរក កម្មវិធីព័ត៌មានសម្លេងម្ចាស់ឆ្នោតកម្ពុជា សម្រាប់ ទូរស័ព្ទដៃ អេនដ្រយដ៍ សូមចូលទៅកាន់ ទីផ្សារ អេនដ្រយដ៍ ហើយស្វែងរកពាក្យថា COMFREL ឬ CVV។

សម្រាប់ **កម្មវិធីព័ត៌មានសម្លេងម្ចាស់ឆ្នោតកម្ពុជា សម្រាប់ទូរស័ព្ទដៃអាយហ្វូន** វិញ ក៏មិនសូវប្លែកពី អេនដ្រដយ៍ដែរ ទូរស័ព្ទដែលមិនមានអក្សរខ្មែរ ក៏អាចអានព័ត៌មាន និងវិដេអូបោះឆ្នោតបាន ហើយកម្មវិធីនេះ មានដាក់អោយម្ចាស់ឆ្នោត ដោនឡូតនៅលើទីផ្សារអែប/អាយធូន ឬ គេហទំព័រ សម្លេងម្ចាស់ឆ្នោតកម្ពុជា ដោយមិនគិតប្រាក់។ ដើម្បីស្វែងរក កម្មវិធីព័ត៌មានសម្លេងម្ចាស់ឆ្នោតកម្ពុជា សម្រាប់ទូរស័ព្ទដៃអាយហ្វូន សូមចូលទៅកាន់ ទីផ្សារអាយធូន (iTunes Store) ហើយស្វែងរកពាក្យថា COMFREL រួចធ្វើការដោនឡូត មកតម្លើងក្នុងទូរសស័ព្ទដៃរបស់លោកអ្នកជាការស្រេច។

កម្មវិធីព័ត៌មានសម្លេងម្ចាស់ឆ្នោតកម្ពុជា នឹងធ្វើកំណែប្រែជាបន្តបន្ទាប់ ដើម្បីធានាបច្ចុប្បន្នភាពព័ត៌មាន និងបច្ចេកវិទ្យាបំពេញចិត្តម្ចាស់ឆ្នោត ក្នុងគោលដៅភ្ជាប់គំលាតព័ត៌មាន រវាងប្រជាពលរដ្ឋជាម្ចាស់ឆ្នោត និងអ្នកតំណាងរាស្ត្រ អ្នកដឹកនាំ ដែលពាក់ព័ន្ធនឹងការចូលរួមអភិវឌ្ឍ និងស្ថាបនាសង្គមប្រជាធិបតេយ្យនៅកម្ពុជា៕

សម្រាប់ព័ត៌មានបន្ថែម សូមទាក់ទង ទូរស័ព្ទលេខ ៖ ០២៣ ៨៨៤ ១៥០ ឬ ០១២ ៩៩៨ ៣៦៤

**ទីស្នាក់ការកណ្តាល** ៖ ផ្ទះលេខ ១៣៨ ផ្លូវ ១២២ សង្កាត់ ទឹកល្អក់ ១ ខណ្ឌ ទួលគោក រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា

**Central Office** : #138, Street. 122, Teuk Laak I, Tuol Kork, Phnom Penh, CAMBODIA.

**P.O. Box** 1145, **Phone** : (855) 23 884 150 **Fax**: (855) 23 885 745 **E-mail** : comfrel@online.com.kh **Website**: www.comfrel.org

**ចក្ខុវិស័យ** ៖ សង្គមប្រជាធិបតេយ្យមួយដែលដំណើរការប្រជាធិបតេយ្យូបនីយកម្ម ជាពិសេសរាល់ការបោះឆ្នោតតាមលក្ខណៈប្រជាធិបតេយ្យ ត្រូវបានលើកតម្កើង និងមានគុណភាពដែលនាំមកនូវផលប្រយោជន៍ជូនដល់ប្រជាពលរដ្ឋ

**Vision** : A democratic society that democratization in particular democratic elections are promoted and qualified to bring benefits to people.